# នមស្សការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ សារីរិកធាតុ មហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរទីកដោយលំឧត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋានទានានោះទាំងអស់ ។
ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ ។
សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិទ្ធ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង

វត្តធម្មារាម



ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុខ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២